# PROTOCOL
# ON COOPERATION BETWEEN THE CENTRAL ELECTION COMMISSION OF THE RUSSIAN FEDERATION AND THE NATIONAL ELECTION COMMITTEE OF THE KINGDOM OF CAMBODIA
# (KHMER VERSION)

# ពិធីសារ

# ស្តីពី

# កិច្ចសហប្រតិបត្តិការ

# រវាង

# គណៈកម្មការកណ្តាលរៀបចំការបោះឆ្នោតនៃសហព័ន្ធរុស្ស៊ី

# និង

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា

# ពិធីសារ
# ស្តីពី
# កិច្ចសហប្រតិបត្តិការ
# រវាង
# គណៈកម្មការកណ្តាលរៀបចំការបោះឆ្នោតនៃសហព័ន្ធរុស្ស៊ី
# និង
# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា

គណៈកម្មការកណ្តាលរៀបចំការបោះឆ្នោតនៃសហព័ន្ធរុស្ស៊ី និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីពេលនេះតទៅ ហៅកាត់ថា "ភាគីទាំងពីរ"

*ដោយពិចារណាលើ*ទំនាក់ទំនងដែលបានបង្កើតឡើងរវាងភាគីទាំងពីរ

*ក្រោយពីបានបញ្ជាក់ឡើងវិញនូវ*ការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ និងនិយាមស្តីពីសិទ្ធិមនុស្សដែលបានទទួលស្គាល់កន្លងមក

*ដោយសម្តែងនូវជំនឿរបស់ខ្លួន*ថា ការបោះឆ្នោតដោយសេរី ពិតប្រាកដ ប្រកបដោយគណនេយ្យភាព និងតាមកាលកំណត់ ផ្អែកលើមូលដ្ឋាននៃការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពនិយាមស្តីពីសិទ្ធិបោះឆ្នោត គឺជាធាតុផ្សំដ៏សំខាន់នៃដំណើរការប្រជាធិបតេយ្យ

*ក្នុងគោលបំណង*ពង្រឹង និងអភិវឌ្ឍកិច្ចសហប្រតិបត្តិការដើម្បីពង្រឹងច្បាប់ស្តីពីការបោះឆ្នោត ព្រមទាំងលើកកម្ពស់នូវវប្បធម៌អ្នកចូលរួមក្នុងដំណើរការបោះឆ្នោតតាមផ្លូវច្បាប់ និងបង្កើតប្រព័ន្ធបច្ចេកវិទ្យានៃការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិចទំនើប

*ដោយពិចារណាលើ*សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការរបស់ភាគីទាំងពីរ ដែលជាផ្នែកដ៏សំខាន់មួយនៃទំនាក់ទំនងរវាងរដ្ឋទាំងពីរ

**បានយល់ឃើញដូចខាងក្រោម៖**

១. កិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ត្រូវបានអនុវត្តដោយឈរលើមូលដ្ឋាននៃការជឿទុកចិត្ត សមភាព និងផលប្រយោជន៍ទៅវិញទៅមក ការគោរព និងការប្រតិបត្តិតាមច្បាប់រដ្ឋរបស់ភាគីនីមួយៗ។

២. ក្នុងគោលបំណងពង្រឹងច្បាប់ជាតិស្តីពីការបោះឆ្នោត និងការធ្វើប្រជាមតិ និងការអនុវត្តជាក់ស្តែងក្នុងការត្រៀមរៀបចំ និងរៀបចំការបោះឆ្នោត និងការធ្វើប្រជាមតិ នៅតាមថ្នាក់នានា ភាគីទាំងពីរនឹងបង្កើតកិច្ចសហប្រតិបត្តិការដូចខាងក្រោម៖

- សកម្មភាពនៃស្ថាប័នរៀបចំការបោះឆ្នោត ដើម្បីធានាសម្រេចឱ្យបាននូវសិទ្ធិបោះឆ្នោត
- បង្កើនកម្រិតវិជ្ជាជីវៈរបស់អ្នករៀបចំការបោះឆ្នោត ព្រមទាំងវប្បធម៌ខាងផ្លូវច្បាប់របស់អ្នកបោះឆ្នោត
- ធានាសិទ្ធិរបស់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការបោះឆ្នោត ក្នុងការធ្វើយុទ្ធនាការឃោសនា ដោយការប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយមហាជន
- ផ្តល់ហិរញ្ញប្បទានសម្រាប់ដំណើរការបោះឆ្នោត ពោលគឺ យន្តការច្បាប់ និងការរៀបចំ ដើម្បីការរក្សា ឱ្យបាន និងគ្រប់គ្រងដំណើរការបោះឆ្នោត

- ការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទំនើបស្តីពីការបោះឆ្នោត និងបច្ចេកវិទ្យាព័ត៌មាន ផ្សេងទៀត ព្រមទាំងប្រព័ន្ធស្វ័យប្រវត្តិក្នុងការចុះឈ្មោះ ការក្សាគណនីព័ត៌មាន និងការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោត បរិក្ខារ សម្ភារ និងម៉ាស៊ីនក្នុងការធានាក្សាឱ្យបាននូវដំណើរការបោះឆ្នោត
- ការរៀបចំការបោះឆ្នោតនៅតាមតំបន់ដាច់ស្រយាល

ភាគីទាំងពីរយល់ឃើញថា កិច្ចសហប្រតិបត្តិការនេះ អាចមានវិសាលភាពគ្របដណ្តប់លើទិសដៅផ្សេងទៀត ក្រោមការកំណត់រួមគ្នាលើការបោះឆ្នោត ដែលនឹងសម្រេចដោយកិច្ចសម្របសម្រួលទ្វេភាគី។

៣. កិច្ចសហប្រតិបត្តិការរបស់ភាគីទាំងពីរ អាចអនុវត្តក្នុងទម្រង់ដូចខាងក្រោម៖

- ការផ្លាស់ប្តូរលទ្ធផលនៃការស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងជាក់ស្តែង ដែលទាក់ទងនឹងការត្រៀមរៀបចំ និងការរៀបចំការបោះឆ្នោត សេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោត និងសេចក្តីសន្និដ្ឋានសមស្របរបស់អ្នកជំនាញ
- ការផ្លាស់ប្តូរអ្នកជំនាញផ្នែករៀបចំការបោះឆ្នោត ព្រមទាំងផ្នែកត្រួតពិនិត្យលើការរៀបចំការបោះឆ្នោត ក្នុងគោលបំណងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក និងការសិក្សាស្វែងយល់លើបទពិសោធន៍
- ការរៀបចំ និងការដំណើរការសិក្ខាសាលា សន្និសីទបែបវិទ្យាសាស្ត្រ និងជាក់ស្តែង កិច្ចប្រជុំតុមូល និងព្រឹត្តិការណ៍ផ្សេងទៀត លើប្រធានបទដែលផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក
- ការចាត់បញ្ជូនតំណាងដើម្បីត្រួតពិនិត្យការត្រៀមរៀបចំ និងការរៀបចំការបោះឆ្នោតនៅក្នុងរដ្ឋរបស់ភាគីម្ខាងទៀត
- ការសហការចូលរួមនៅក្នុងសកម្មភាព ដែលអនុវត្តដោយអង្គការវិជ្ជាជីវៈ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងថ្នាក់តំបន់ របស់អ្នករៀបចំការបោះឆ្នោត ព្រមទាំងជាមួយនឹងអង្គការ និងស្ថាប័នដទៃទៀត ដែលមានជំនាញក្នុងវិស័យអភិវឌ្ឍប្រព័ន្ធបោះឆ្នោត សិទ្ធិបោះឆ្នោត និងការការពារសិទ្ធិបោះឆ្នោត ។

៤. ដើម្បីពង្រឹងច្បាប់ជាតិស្តីពីការបោះឆ្នោត និងសកម្មភាពរបស់គណៈកម្មការរៀបចំការបោះឆ្នោត ភាគីទាំងពីរនឹងធ្វើការផ្លាស់ប្តូរបទពិសោធន៍លើបញ្ហាដូចខាងក្រោម៖

- ការក្សាឱ្យបាននូវចរិតនៃការបោះឆ្នោតប្រកបដោយភាពត្រឹមត្រូវ និងបើកចំហ
- ការកំណត់បទប្បញ្ញត្តិច្បាប់ស្តីពីគណបក្សនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងសកម្មភាពដំណើរការបោះឆ្នោត លើការរៀបចំការបោះឆ្នោតជូនស្ថាប័នរដ្ឋ និងរដ្ឋបាលមូលដ្ឋាន
- ការពង្រឹងស្ថាប័នដោយឡែកដែលធ្វើការងារលើច្បាប់ស្តីពីការបោះឆ្នោត និងដែលទាក់ទងនឹងការត្រៀមរៀបចំ និងការរៀបចំការបោះឆ្នោត

ភាគីទាំងពីរ ក៏នឹងផ្លាស់ប្តូរព័ត៌មានស្តីពីបញ្ហានៃការចងក្រងកម្រងបទដ្ឋានអន្តរជាតិស្តីពីការបោះឆ្នោត និងការអនុវត្តបទដ្ឋានទាំងនេះ នៅក្នុងច្បាប់ស្តីពីការបោះឆ្នោត ព្រមទាំងការអនុវត្តការងារជាក់ស្តែងរបស់ស្ថាប័នរៀបចំការបោះឆ្នោត។

៥. ដើម្បីបង្កើនកម្រិតវិជ្ជាជីវៈរបស់អ្នករៀបចំការបោះឆ្នោត ព្រមទាំងវប្បធម៌ខាងផ្លូវច្បាប់របស់អ្នកបោះឆ្នោត ភាគីទាំងពីរនឹងធ្វើការផ្លាស់ប្តូរ៖

- បទពិសោធន៍លើការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អ្នករៀបចំការបោះឆ្នោត លើការបង្កើនវប្បធម៌ខាងផ្លូវច្បាប់របស់អ្នកបោះឆ្នោត លើផែនការ និងកម្មវិធីទាក់ទងនឹងបញ្ហាសមស្រប
- ការអនុវត្តដើម្បីលើកកម្ពស់ និងខ្លឹមសារនៃកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកបោះឆ្នោត (ប្រជាពលរដ្ឋ) នៅតាមតំបន់បោះឆ្នោត
- សម្ភារផ្នែកវិធីសាស្ត្រ ព័ត៌មាន ការវិភាគ និងសម្ភារគាំទ្រ
- បទពិសោធន៍ស្តីពីការបង្កើតសម្ភារសោតទស្សន៍ និងការផលិតសម្ភារផ្សេងទៀត ដែលសមស្របសម្រាប់ទិដ្ឋភាពនានានៃយុទ្ធនាការឃោសនាបោះឆ្នោត។

៦. ដើម្បីធានាសិទ្ធិរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការបោះឆ្នោត នៅក្នុងអំឡុងយុទ្ធនាការឃោសនាបោះឆ្នោត ភាគីទាំងពីរ នឹងធ្វើការផ្លាស់ប្តូរបទពិសោធន៍លើបញ្ហាដូចខាងក្រោម៖

- ទម្រង់ និងមធ្យោបាយនៃការធ្វើយុទ្ធនាឃោសនាការបោះឆ្នោត
- សិទ្ធិ និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការបោះឆ្នោត លើការធ្វើយុទ្ធនាការឃោសនា
- លក្ខណៈពិសេសនៃការធ្វើយុទ្ធនាការឃោសនា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងមិនមែនរដ្ឋ ក្រោមថវិកាចំណាយរបស់រដ្ឋ ឬ សាលាក្រុង និងក្រោមមូលនិធិសម្រាប់ការបោះឆ្នោតរបស់អ្នកពាក់ព័ន្ធក្នុងដំណើរការបោះឆ្នោត។
- អំណាចរបស់គណៈកម្មការរៀបចំការបោះឆ្នោត សកម្មភាពរបស់ស្ថាប័នរដ្ឋ និងស្ថាប័នរដ្ឋបាលមូលដ្ឋាន នៅក្នុងការរៀបចំ និងការរក្សាបាននូវលក្ខខណ្ឌសម្រាប់ការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។

៧. ដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ការបោះឆ្នោត ភាគីទាំងពីរនឹងធ្វើការផ្លាស់ប្តូរបទពិសោធន៍លើបញ្ហាដូចខាងក្រោម៖

- របៀបរបបនៃការបែងចែក និងប្រើប្រាស់មូលនិធិថវិការដ្ឋ
- ការរៀបចំលើការគ្រប់គ្រងនៃការប្រើប្រាស់មូលនិធិថវិការដ្ឋឱ្យចំគោលដៅ ព្រមទាំង ប្រភពទទួល និងមធ្យោបាយចំណាយមូលនិធិសម្រាប់ការបោះឆ្នោតរបស់គណបក្សនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងដំណើរការបោះឆ្នោត
- បច្ចេកទេសនៃការធ្វើគណនេយ្យនៅក្នុងការប្រើប្រាស់មូលនិធិថវិការដ្ឋ ដោយគណៈកម្មការរៀបចំការបោះឆ្នោត ព្រមទាំងអ្នកចូលរួមផ្សេងទៀតក្នុងដំណើរការបោះឆ្នោត។

៨. ដើម្បីអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទំនើបផ្សេងទៀត និងបរិក្ខារសម្រាប់ការបោះឆ្នោត ភាគីទាំងពីរ នឹងធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងសម្ភារក្នុងទិសដៅដូចខាងក្រោម៖

- ការធ្វើប្រព័ន្ធស្វ័យប្រវត្តិកម្មនៃដំណើរការរាប់សន្លឹកឆ្នោត និងការចុះបញ្ជីអ្នកបោះឆ្នោត
- ការធ្វើប្រព័ន្ធស្វ័យប្រវត្តិកម្មនៃដំណើរការកំណត់អត្តសញ្ញាណកម្មអ្នកបោះឆ្នោត បច្ចេកវិទ្យា និងបរិក្ខារ
- បច្ចេកវិទ្យា និងបរិក្ខារសម្រាប់ការបោះឆ្នោតដោយស្វ័យប្រវត្តិ ការពិនិត្យផ្ទៀងផ្ទាត់ និងការបូកសរុបលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត
- បច្ចេកវិទ្យា និងបរិក្ខារសម្រាប់ចាត់ចែង រក្សាទុក និងផ្ទេរព័ត៌មាន សម្រាប់ការបង្កើតមូលដ្ឋានទិន្នន័យ និងសម្ភារបន្ទាប់បន្សំ និងរួមផ្សំផ្សេងទៀត ម៉ាស៊ីន និងឧបករណ៍ទាក់ទង នឹងការរៀបចំដំណើរការបោះឆ្នោត។

៩. ដើម្បីសម្រេចបាននូវការរៀបចំដែលមានស្រាប់ ភាគីទាំងពីរនឹងជួយគ្នាទៅវិញទៅមកលើការរៀបចំបច្ចេកវិទ្យា វិធីសាស្ត្រ និងជំនួយផ្សេងទៀតដែលចាំបាច់។

- សោហ៊ុយចំណាយទាក់ទងនឹងការផ្លាស់ប្តូរអ្នកជំនាញ និងក្នុងការចូលរួមព្រឹត្តិការណ៍ដែលរៀបចំឡើងដោយភាគីម្ខាងទៀត ត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម លើកលែងមានការព្រមព្រៀងដោយឡែកជាមុន៖
- ភាគីអ្នកដឹកនាំត្រូវរ៉ាប់រងថ្លៃចំណាយលើការដឹកជញ្ជូន ទាក់ទងនឹងការធ្វើដំណើររបស់គណៈប្រតិភូទៅកាន់ប្រទេសដែលចុះបំពេញការងារ
- ភាគីម្ចាស់ផ្ទះ ជាអ្នករ៉ាប់រងលើថ្លៃចំណាយអាហារហូបចុក និងការស្នាក់នៅរបស់គណៈប្រតិភូទាក់ទងនឹងកម្មវិធីស្នាក់នៅ។

១០. ការធ្វើវិសោធនកម្ម ឬ ការកែសម្រួលពិធីសារនេះ អាចធ្វើទៅបាន ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងភាគីទាំងពីរ។

១១. ពិធីសារនេះនឹងចូលជាធរមានគិតចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខានេះតទៅ ក្នុងរយៈពេលប្រាំ (៥) ឆ្នាំ។

ក្រោយផុតរយៈពេលនេះ ពិធីសារនេះនឹងបន្តសុពលភាពដោយស្វ័យប្រវត្តិរយៈពេលប្រាំ (៥) ឆ្នាំ ទៀត លើកលែងតែភាគីណាមួយជូនដំណឹងភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមិនតិចជាងប្រាំមួយ (៦) ខែ នៅមុនផុតសុពលភាព បង្ហាញគោលបំណងចង់លុបចោលពិធីសារនេះ។

១២. ពិធីសារមិនមែនជាសន្ធិសញ្ញាអន្តរជាតិទេ ហើយពុំបង្កើតសិទ្ធិ និងកាតព្វកិច្ច ក្រោមច្បាប់អន្តរជាតិនោះឡើយ។

ធ្វើនៅទីក្រុងម៉ូស្គូ ថ្ងៃទី...១៧...ខែមីនា ឆ្នាំ២០១៨ ចំនួនបី (៣) ច្បាប់ដើម មួយ (១) ច្បាប់ជាភាសាខ្មែរ ជាភាសារុស្ស៊ី និងមួយ (១) ច្បាប់ទៀត ជាភាសាអង់គ្លេស។

**តំណាងគណៈកម្មការកណ្តាលរៀបចំការបោះឆ្នោតនៃសហព័ន្ធរុស្ស៊ី**
**ហត្ថលេខា**

**H.E. Ms. Ella Pamfilova**

**តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា**
**ហត្ថលេខា**

**ឯ.ឧ. ឌឹម សុវណ្ណារុំ**